# ខិត្តប័ណ្ណព័ត៌មាន - ដីកាសុវត្ថិភាពសហគមន៍សាលារៀនដែលកំពុងដំណើរការ

## តើអ្វីទៅជាដីកាសុវត្ថិភាពសហគមន៍សាលារៀនដែលកំពុងដំណើរការ?

មនុស្សមួយចំនួនដូចជានាយកសាលា និងបុគ្គលិកក្រសួងអប់រំ និងបណ្ដុះបណ្ដាល ត្រូវបានគេហៅថា "បុគ្គលដែលមានសិទ្ធិអំណាច"។ ពួកគេមានអំណាចក្នុងការចេញដីកាដែលកំណត់ច្បាប់ទំលាប់នានាដើម្បីឱ្យអ្នកអនុលោមតាមពេលណាដែលអ្នកទៅ ឬទាក់ទិនជាមួយសាលារៀន។

ដីកាអាចបញ្ឈប់អ្នកពីការចូល ឬស្នាក់នៅក្នុងបរិវេណសាលា ឬកន្លែងផ្សេងទៀតដែលសកម្មភាពសាលារៀនកើតឡើង។ ដីកាអាចចែងថា អ្នកមិនត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តរបៀបជាក់លាក់មួយចំពោះមនុស្សមួយចំនួន ក្នុងពេលជាក់លាក់ណាមួយនៅសាលារៀន ឬកន្លែងផ្សេងទៀតដែលសកម្មភាពសាលារៀនកើតឡើង។ ដីកាអាចរួមបញ្ចូលកាលៈទេសៈពិសេសនានាដូចជាពេលវេលា ឬផ្នែកផ្សេងទៀតដែលមិនមានក្នុងដីកា។

អ្នកត្រូវបានគេប្រគល់ដីកានេះដើម្បីឱ្យគ្រូបង្រៀន សិស្ស និងមនុស្សផ្សេងទៀតនៅសាលារៀនមានអារម្មណ៍សុវត្ថិភាព។ ព័ត៌មានបន្ថែមអំពីដីកាសុវត្ថិភាពសហគមន៍សាលារៀនអាចរកបាននៅទីនេះ។ អ្នកអាចមើលវីដេអូនៅទីនេះ ដើម្បីជួយអ្នកឱ្យយល់ដឹងពីអ្វីដែលដីកាសុវត្ថិភាពសហគមន៍សាលារៀនធ្វើ។

## តើដីកាត្រូវបានដាក់ដំណើរការរយៈពេលប៉ុន្មាន?

ដីកាក៏ប្រាប់អ្នកផងដែរពីរយៈពេលដែលច្បាប់ទំលាប់ទាំងនេះនឹងត្រូវបានដាក់ដំណើរការ។ រយៈពេលវែងបំផុតដែលដីកាអាចត្រូវបានដាក់ដំណើរការគឺ 12 ខែ។

## តើខ្ញុំត្រូវប្រាប់សាលារៀនដោយរបៀបណា ថាខ្ញុំមិនយល់ស្របជាមួយនឹងដីកាដែលកំពុងត្រូវបានធ្វើឡើង?

មុនពេលបុគ្គលដែលមានសិទ្ធិអំណាចអាចធ្វើដីកា ពួកគេត្រូវតែប្រាប់អ្នកឱ្យបានដឹងថា ពួកគេកំពុងគិតអំពីការធ្វើដីកាមួយ ហើយពីហេតុផលដែលពួកគេគិតថាពួកគេនឹងធ្វើដីកា។ អ្នកអាចធ្វើ 'ការដាក់ស្នើ' មួយទៅកាន់បុគ្គលដែលមានសិទ្ធិអំណាច ដើម្បីពន្យល់ពីហេតុផលដែលអ្នកបានប្រព្រឹត្តក្នុងរបៀបជាក់លាក់មួយ វិធីដែលវានឹងប៉ះពាល់ដល់អ្នក ឬកូនរបស់អ្នក ឬអ្វីផ្សេងទៀតដែលពួកគេត្រូវការដឹង ដើម្បីពួកគេអាចសម្រេចចិត្ត ថាតើត្រូវធ្វើដីកាឬអត់។ ឧទាហរណ៍ អ្នកប្រហែលជាចង់ប្រាប់បុគ្គលដែលមានសិទ្ធិអំណាចនោះ ថាកូនរបស់អ្នកមានពិការភាពដើម្បីឱ្យពួកគេអាចធ្វើការរៀបចំនានា ដើម្បីធ្វើឱ្យប្រាកដថា អ្នកអាចបន្តគាំទ្រពួកគេឱ្យទៅសាលារៀនបាន។

អ្នកមានពេល 7 ថ្ងៃដើម្បីធ្វើការដាក់ស្នើ បន្ទាប់ពីត្រូវបានប្រាប់ដោយបុគ្គលដែលមានសិទ្ធិអំណាច ថាពួកគេកំពុងគិតអំពីការធ្វើដីកា។ អ្នកក៏អាចស្នើសុំពេលវេលាបន្ថែមទៀតផងដែរដើម្បីធ្វើការដាក់ស្នើ ប្រសិនបើអ្នកត្រូវការ។

ការដាក់ស្នើជាលាយលក្ខណ៍អក្សរអាចធ្វើឡើងជាអ៊ីមែល ឬលិខិតទៅកាន់បុគ្គលដែលមានសិទ្ធិអំណាច។ អ្នកអាចប្រើគំរូដែលមាននៅលើគេហទំព័ររបស់ក្រសួងអប់រំ និងបណ្ដុះបណ្ដាលនៅទីនេះ។

ប្រសិនបើអ្នកមិនចង់សរសេរការដាក់ស្នើទេ អ្នកអាចស្នើសុំឱ្យដាក់ជាពាក្យសំដីជំនួសវិញ។ អ្នកក៏អាចស្នើសុំឱ្យអ្នកផ្សេងធ្វើការដាក់ស្នើជូនអ្នកផងដែរ ដូចជាបុគ្គលគាំទ្រពិការភាពរបស់អ្នក ឬអ្នកបកប្រែភាសាផ្ទាល់មាត់ជាដើម។

## ប្រសិនបើខ្ញុំមានកូននៅសាលារៀន តើនឹងមានអ្វីកើតឡើងចំពោះពួកគេឥឡូវនេះ ដែលខ្ញុំត្រូវតែអនុលោមតាមដីកាដែលកំពុងដំណើរការ?

សាលារៀនរបស់អ្នកបានគិតដោយប្រុងប្រយ័ត្ន អំពីរបៀបដែលដីកានឹងប៉ះពាល់ដល់កូនរបស់អ្នក និងរបៀបដែលអ្នកថែទាំពួកគេ។ ដីកាមិនមានន័យថា បញ្ឈប់អ្នកពីការថែទាំពួកគេ ឬពាក់ព័ន្ធនឹងការអប់រំរបស់ពួកគេនោះទេ។

សាលារៀនរបស់អ្នកនឹងផ្តល់ឱ្យអ្នកនូវ 'ពិធីការទំនាក់ទំនង និងការចូលប្រើប្រាស់' ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការប្រគល់ដីកាជូនអ្នក។ នេះនឹងកំណត់ពី៖

- របៀបដែលអ្នកអាចត្រូវបានគេប្រាប់អំពីការអប់រំរបស់កូនអ្នក
- របៀបដែលកូនរបស់អ្នកអាចបន្តទៅសាលារៀន និងចូលរួមក្នុងសកម្មភាពសាលារៀនដោយសុវត្ថិភាព
- អ្វីដែលពួកគេនឹងធ្វើដើម្បីប្រាកដថា កូនរបស់អ្នកត្រូវបានគាំទ្រ និងថែទាំ។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនអនុលោមតាមដីកា?

ប្រសិនបើអ្នកមិនអនុលោមតាមច្បាប់ទំលាប់នានាដែលមានចែងក្នុងដីកាទេ សាលារៀនអាចដាក់ពាក្យទៅតុលាការដំបូង (Magistrate’s Court) ដើម្បីបង្ខំអ្នកឱ្យអនុលោមតាមដីកានោះ។

ប្រសិនបើតុលាការដំបូងរកឃើញថាអ្នកខុសដោយមិនអនុលោមតាមដីកា ពួកគេអាច៖

- តម្រូវឱ្យអ្នកបង់ប្រាក់ពិន័យ
- តម្រូវឱ្យអ្នកអនុលោមតាមដីកា
- តម្រូវឱ្យអ្នកចាត់វិធានការជាក់លាក់ ដើម្បីអនុលោមតាមដីកា
- តម្រូវឱ្យអ្នកធ្វើអ្វីផ្សេងទៀតដែលតុលាការគិតថា សមស្រប។

អ្នកនឹងមិនត្រូវជាប់ពន្ធនាគារ មិនជាប់កំណត់ត្រាបទឧក្រិដ្ឋ ឬមិនទទួលការពិន័យបទឧក្រិដ្ឋចំពោះការមិនអនុលោមតាមដីកាទេ។

## ចុះបើខ្ញុំត្រូវការឱ្យគេផ្លាស់ប្តូរដីកា?

ប្រសិនបើអ្នកចង់ឱ្យគេដកហូតច្បាប់ទំលាប់នានានៅក្នុងដីកា ឬផ្លាស់ប្តូរដីកា អ្នកអាចស្នើសុំបុគ្គលដែលមានសិទ្ធិអំណាចដែលបានធ្វើដីកា ដើម្បីធ្វើការផ្លាស់ប្តូរច្បាប់ទំលាប់ទាំងនោះ។ ប្រសិនបើបុគ្គលដែលមានសិទ្ធិអំណាចយល់ព្រម ពួកគេត្រូវផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងជាលាយលក្ខណ៍អក្សរនៃដីកាដែលបានផ្លាស់ប្តូរនោះ។ ប្រសិនបើពួកគេមិនយល់ស្របទេ ពួកគេត្រូវធ្វើតាមលក្ខខណ្ឌតម្រូវនានាដូចគ្នានឹងពេលធ្វើដីកាដែលកំពុងដំណើរការ។

ប្រសិនបើបុគ្គលដែលមានសិទ្ធិអំណាចចង់បន្ថែមច្បាប់ទំលាប់ថ្មីទៅក្នុងដីកា ពួកគេត្រូវធ្វើតាមលក្ខខណ្ឌតម្រូវនានាដូចគ្នានឹងពេលធ្វើដីកាដែលកំពុងដំណើរការ។

**ចុះបើខ្ញុំចង់ប្ដឹងតវ៉ាមិនយល់ស្របចំពោះដីកា?**

អ្នកអាចដាក់ពាក្យសុំទៅសាលារៀនរបស់អ្នក ដើម្បីប្ដឹងតវ៉ាមិនយល់ស្របចំពោះដីកាសម្រាប់ហេតុផលនានាដូចខាងក្រោម:

- ប្រសិនបើអ្នកមិនយល់ព្រមថាដីកាគួរតែត្រូវបានធ្វើប្រឆាំងនឹងអ្នក
- ប្រសិនបើអ្នកបានស្នើសុំឱ្យបុគ្គលដែលមានសិទ្ធិអំណាចផ្លាស់ប្ដូរអ្វីមួយនៅក្នុងដីកា ប៉ុន្តែពួកគេបានបដិសេធ ហើយអ្នកមិនពេញចិត្តនឹងការសម្រេចចិត្តនេះទេ
- ប្រសិនបើបុគ្គលដែលមានសិទ្ធិអំណាចបានផ្លាស់ប្ដូរដីកា ហើយអ្នកមិនពេញនឹងការសម្រេចចិត្តនេះទេ
- ប្រសិនបើបុគ្គលដែលមានសិទ្ធិអំណាចបានសម្រេចចិត្តមិនលុបចោលដីកា ហើយអ្នកមិនពេញចិត្តនឹងការសម្រេចចិត្តនេះទេ។

ការសម្រេចចិត្តសើរើតពិនិត្យផ្ទៃក្នុងលើការសម្រេចចិត្តអាចត្រូវការពេល 28 ថ្ងៃ ចាប់ពីពេលដែលពាក្យសុំរបស់អ្នកត្រូវបានផ្ញើទៅនាយកសាលា។ ពេលវេលានេះត្រូវបានប្រើដើម្បីវាយតម្លៃដោយប្រុងប្រយ័ត្ន នូវហេតុផលនៅពីក្រោយដីកាដែលត្រូវបានធ្វើឡើងប្រឆាំងនឹងអ្នក និងហេតុផលនានាដែលបានផ្ដល់នៅក្នុងការដាក់ស្នើរបស់អ្នក។

អ្នកសើរើពិនិត្យផ្ទៃក្នុងអាចធ្វើការផ្លាស់ប្ដូរដីកា លុបចោលដីកា ឬមិនធ្វើអ្វីសោះ។ នៅពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង អ្នកនឹងត្រូវបានជូនដំណឹងតាមអ៊ីមែល និង/ឬតាមប្រៃសណីយ៍ ហើយអ្នកនឹងទទួលបានច្បាប់ចម្លងនៃហេតុផលនានាចំពោះលទ្ធផលសើរើពិនិត្យផ្ទៃក្នុង ដើម្បីជួយអ្នកឱ្យយល់ដឹងពីការសម្រេចចិត្តដែលបានធ្វើឡើង។

ប្រសិនបើអ្នកមិនពេញចិត្តចំពោះលទ្ធផលនៃការសើរើពិនិត្យផ្ទៃក្នុង អ្នកអាចប្ដឹងតវ៉ាមិនយល់ស្របចំពោះការសម្រេចចិត្តនេះទៅតុលាការរដ្ឋប្បវេណី និងរដ្ឋបាលរដ្ឋវិចថូរៀ។ អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីរឿងនេះនៅលើគេហទំព័ររបស់ក្រសួងអប់រំ និងបណ្ដុះបណ្ដាលនៅទីនេះ។

**ចុះបើខ្ញុំត្រូវការអ្នកបកប្រែភាសាសរសេរ/អ្នកបកប្រែភាសាផ្ទាល់មាត់ ឬជំនួយផ្សេងទៀត?**

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាសរសេរ អ្នកបកប្រែភាសាផ្ទាល់មាត់ ឬអ្នកគាំទ្រ អ្នកអាចប្រាប់នាយកសាលាដែលអាចជួយអ្នកទទួលបានការគាំទ្រ។

ប្រសិនបើកូនរបស់អ្នកទៅសាលារៀនរដ្ឋ អ្នកក៏អាចទាក់ទងការិយាល័យប្រចាំតំបន់របស់ក្រសួងអប់រំ និងបណ្ដុះបណ្ដាលសម្រាប់ការគាំទ្របន្ថែមផងដែរ។

| | |
|---|---|
| តំបន់ខាងជើងឆៀងខាងកើតរដ្ឋវិចថូរៀ<br>ទូរសព្ទ៖ 1300 333 231<br>អ៊ីមែល៖ nevr@education.vic.gov.au | តំបន់ខាងជើងឆៀងខាងលិចរដ្ឋវិចថូរៀ<br>ទូរសព្ទ៖ 1300 338 691<br>អ៊ីមែល៖ nwvr@education.vic.gov.au |
| តំបន់ខាងត្បូងឆៀងខាងកើតរដ្ឋវិចថូរៀ | តំបន់ខាងត្បូងឆៀងខាងលិចរដ្ឋវិចថូរៀ |

| | |
|---|---|
| អ៊ីមែល៖ 1300 338 738<br>អ៊ីមែល៖ sevr@education.vic.gov.au | ទូរសព្ទ៖ 1300 333 232<br>អ៊ីមែល៖ swvr@education.vic.gov.au |

## ចុះបើខ្ញុំចង់បានព័ត៌មានបន្ថែមទៀត?

អ្នកអាចចូលទៅកាន់គេហទំព័ររបស់ក្រសួងអប់រំ និងបណ្តុះបណ្តាលនៅទីនេះ សម្រាប់ព័ត៌មានបន្ថែម។